ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៧៣០៨ អសក.ពកក.ពផ

# សេចក្ដីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ផ្លាស់ប្ដូរ តម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្ដាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី០៧ ខែសីហា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ P018 ស្ថិតនៅភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវវេងស្រេង ចាប់ពីភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវកែវចិន្ដា ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។

២. ថ្ងៃសុក្រទី០៨ ខែសីហា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិសំរោងទាវ ភូមិព្រៃមូល ក្នុងសង្កាត់ក្រាំងធ្នង់ ភូមិស្រែជំរៅ ភូមិកប់ស្រូវ ភូមិត្រពាំងពោធិ ភូមិត្រពាំងវែង ភូមិស្វាយចេក ក្នុងសង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិអង្គត្រកៀត ក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ និង (៣) តំបន់ភ្លើងលេខ OP022 ស្ថិតនៅតាមបណ្ដោយផ្លូវលេខ៥៩៨ ក្នុងសង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៣. ថ្ងៃសៅរ៍ទី០៩ ខែសីហា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវវេងស្រេង ចាប់ពីភូមិទ្រា ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជើងឯក ចាប់ពីភូមិម័ល រហូតដល់ភូមិបាគូ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤. ថ្ងៃអាទិត្យទី១០ ខែសីហា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉ោ០០ ដល់ម៉ោង១៧ម៉ោ០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ P057 ស្ថិតនៅក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវវេងស្រេង ចាប់ពីភូមិទ្រា ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវជើងឯក ចាប់ពីភូមិម័ល រហូតដល់ភូមិបាគូ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមសម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ . ថ្ងៃទី០៥.......ខែសីហា...ឆ្នាំ២០១៤

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករងទី១**

ឆឹង-អ៊ុង